ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :..៦៧...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សាកលវិទ្យាល័យញូវតុនធីឡាយ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក.ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ. ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញលិខិតស្នើសុំ របស់លោក ជា ធីឡាយ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០០៤
- តាមសំណើរបស់ក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

មាត្រា ១ : ទទួលស្គាល់ គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា សាកលវិទ្យាល័យញូវតុនធីឡាយ (Newton Thilay University) ហៅកាត់ជាភាសាខ្មែរ "ស.ញ.ធ" និងហៅកាត់ជាភាសាអង់គ្លេស

"N.T.U" ។ សាកលវិទ្យាល័យញូវតុនធីឡាយ មានទីតាំងស្ថិតនៅអាគារលេខ ១០០ វិថីចាំស៊ូវ ផ្លូវលេខ ៥១ កែងនឹងផ្លូវលេខ ២០០ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

មាត្រា ២ : សាកលវិទ្យាល័យញូវតុនធីឡាយ មានតួនាទីជាមជ្ឈមណ្ឌលបណ្តុះបណ្តាលធនធានមនុស្ស និងស្រាវជ្រាវ វប្បធម៌ វិទ្យាសាស្ត្រ បច្ចេកទេស និងស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៣ : សាកលវិទ្យាល័យញូវតុនធីឡាយ ធ្វើការបណ្តុះបណ្តាលថ្នាក់ :

- បរិញ្ញាប័ត្ររង សិក្សារយៈពេលយ៉ាងតិច ២ ឆ្នាំ ត្រូវនឹង ៧០ ក្រេឌីតជាមធ្យម
- បរិញ្ញាប័ត្រ សិក្សារយៈពេលយ៉ាងតិច ៤ ឆ្នាំ ត្រូវនឹង ១៤០ ក្រេឌីតជាមធ្យម និង ថ្នាក់អនុបណ្ឌិត

មាត្រា ៤ : ក្នុងដំណើរការចាប់ផ្តើមនេះ សាកលវិទ្យាល័យញូវតុនធីឡាយ មានមហាវិទ្យាល័យចំនួនបួន :

១. មហាវិទ្យាល័យភាសាបរទេស ដែលមានឯកទេស អប់រំភាសាអង់គ្លេស

២. មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម ដែលមានឯកទេស នីតិសាស្ត្រ រដ្ឋបាលសាធារណៈ វិទ្យាសាស្ត្រនយោបាយ និង កិច្ចការសាធារណៈនិងអន្តរជាតិ

៣. មហាវិទ្យាល័យគ្រប់គ្រងនិងសេដ្ឋកិច្ច ដែលមានឯកទេស គ្រប់គ្រង គណនេយ្យ ទីផ្សារ គ្រប់គ្រងពាណិជ្ជកម្មអន្តរជាតិ ហិរញ្ញវត្ថុនិងធនាគារ គ្រប់គ្រងធនធានមនុស្ស គ្រប់គ្រងទេសចរណ៍ គ្រប់គ្រងសណ្ឋាគារនិងបដិសណ្ឋារកិច្ច គ្រប់គ្រងអភិវឌ្ឍន៍ និងអភិវឌ្ឍសេដ្ឋកិច្ច

៤. មហាវិទ្យាល័យព័ត៌មានវិទ្យា ដែលមានឯកទេស កម្មវិធីកុំព្យូទ័រ ជួសជុលនិងតំលើងប្រព័ន្ធ ដាតាបេសកុំព្យូទ័រ និង បច្ចេកវិទ្យាទូរគមនាគមន៍ ។

ទៅអនាគត សាកលវិទ្យាល័យញូវតុនធីឡាយ អាចពង្រីក ឬប្តូរទីតាំង ឬបើកមហាវិទ្យាល័យ សាខា ឯកទេស និងប្រភេទបណ្តុះបណ្តាលដទៃទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាតពីក្រសួង អប់រំ យុវជន និងកីឡា ។

មាត្រា ៥ : សាកលវិទ្យាល័យញូវតុនធីឡាយ ដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ និង មានក្រុមប្រឹក្សាវិទ្យាសាស្ត្រមួយដែលមានភារកិច្ច អនុម័តលើកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធ ។

មាត្រា ៦ : សាកលវិទ្យាល័យញូតុនធីឡាយ ត្រូវអនុវត្តតាមបទដ្ឋាន របស់ក្រសួងអប់រំ យុវជន និងកីឡា និងរាជរដ្ឋាភិបាលដែលបានកំណត់លើសកម្មភាព ដើម្បីធានាគុណភាពនៃការបណ្តុះបណ្តាល ។

មាត្រា ៧ : តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែង របស់សាកលវិទ្យាល័យញូវតុនធីឡាយ ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យ និងមានការឯកភាព ពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៨ : សាកលវិទ្យាធិការនៃសាកលវិទ្យាល័យញូវតុនធីឡាយ មានភារកិច្ចទទួលខុសត្រូវ នៅចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យ និងធានាអោយបាននូវសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម។

មាត្រា ៩ : និស្សិតដែលរៀនចប់កម្មវិធីសិក្សារបស់ សាកលវិទ្យាល័យញូវតុនធីឡាយនិងទទួលបានជោគជ័យ ក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលបានសញ្ញាប័ត្រ តាមកំរិត និងតាមឯកទេស ដែលបានសិក្សា ។ សញ្ញាប័ត្រនេះ ផ្តល់អោយដោយសាកលវិទ្យាល័យញូវតុនធីឡាយ ហើយត្រូវបានទទួលស្គាល់ពីក្រសួង

អប់រំ យុវជននិងកីឡា ក្នុងករណី សាកលវិទ្យាល័យ បំពេញ និងអនុវត្តបាន តាមគោលការណ៍កំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ១០ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុករាជធានីភ្នំពេញ អគ្គនាយកដ្ឋាន នាយកដ្ឋានពាក់ព័ន្ធ និងសាកលវិទ្យាល័យញូវតុនធីឡាយត្រូវទទួលបន្ទុកអនុវត្ត តាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី ១៥ ខែ ១៧ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាក្រុងភ្នំពេញ
  " ដើម្បីជ្រាបជាព័ត៌មាន "
- ដូចមាត្រា ១០ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ